ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
លេខ..........................

# សេចក្តីថ្លែងការណ៍
# អ្នកនាំពាក្យក្រសួងការពារជាតិ

ជាថ្មីម្តងទៀត ក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា សូមប្រកាសថ្កោលទោស និងច្រានចោលទាំងស្រុងចំពោះរបាយការណ៍ញុះញង់គ្មានមូលដ្ឋានបែបវិទ្ធង្សនារបស់ មន្ទីរចារកម្មជាតិសហរដ្ឋអាមេរិក ដែលផ្សព្វផ្សាយ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩ ដើម្បីបង្កឱ្យមានការភាន់ច្រឡំដល់ សាធារណមតិជាតិ និងអន្តរជាតិ មកលើឯករាជ្យភាពរបស់ព្រះរាជាណាចក្រកម្ពុជា។

របាយការណ៍ ស្តីពី ការវាយតម្លៃលើការគំរាមកំហែងទូទាំងពិភពលោករបស់សហរដ្ឋអាមេរិក បានឆ្លុះបញ្ចាំងយ៉ាងច្បាស់នូវចេតនាអាក្រក់មួយ ក្នុងការជ្រៀតជ្រែកដ៏ធ្ងន់ធ្ងរចំពោះ កិច្ចការផ្ទៃក្នុងរបស់រដ្ឋអធិបតេយ្យ និងជាការប៉ុនប៉ងបំផ្លិចបំផ្លាញលាបពណ៌មកលើ ភាពឯករាជ្យ អព្យាក្រឹត្យអចិន្ត្រៃយ៍ របស់ព្រះរាជាណាចក្រកម្ពុជា ទោះបីជាមាន ការបំភ្លឺផ្លូវច្បាប់ និងបញ្ជាក់ជំហរយ៉ាងច្បាស់លាស់ ម្តងហើយម្តងទៀតពីសំណាក់ រាជរដ្ឋាភិបាលកម្ពុជា ចំពោះវត្តមានកងទ័ពបរទេសក៏ដោយ។

ព្រះរាជាណាចក្រកម្ពុជា បានឆ្លងកាត់សង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃ ដែលផ្តើមចេញពី រដ្ឋប្រហារគាំទ្រដោយសហរដ្ឋអាមេរិក ឆ្នាំ១៩៧០ និងធ្លាប់រងគ្រោះដោយវត្តមានកងទ័ពបរទេសនៅលើទឹកដី បានធ្វើប្រជាជនយល់ដឹងកាន់តែច្បាស់អំពីតម្លៃសន្តិភាព មិនចង់ឱ្យប្រវត្តិសាស្ត្រនេះវិលមកជាថ្មី គ្រាដែលប្រទេសកំពុងមានសន្តិភាពពេញលេញនោះឡើយ ហើយកម្ពុជាក៏មិនចាំបាច់កែរដ្ឋធម្មនុញ្ញ ដើម្បីទទួលវត្តមានកងទ័ពបរទេសនោះដែរ។

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ធ្លាប់បានមានប្រសាសន៍បញ្ជាក់ជំហរយ៉ាងច្បាស់ហើយថា ទោះជាកម្ពុជាពេលនេះ មានលទ្ធភាពកែប្រែរដ្ឋធម្មនុញ្ញក៏ដោយ ក៏សម្តេចតេជោនាយករដ្ឋមន្ត្រី ប្រកាសមិនកែប្រែរដ្ឋធម្មនុញ្ញ ដើម្បីអនុញ្ញាតឱ្យមានមូលដ្ឋានទ័ពបរទេស ឬបញ្ជូនយោធាកម្ពុជាទៅក្រៅប្រទេស ក្រៅពីបេសកកម្មជាមួយអង្គការសហប្រជាជាតិនោះឡើយ។

ក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា ស្វាគមន៍ជានិច្ច ចំពោះមន្ទីរចារកម្មជាតិសហរដ្ឋអាមេរិក ដែលមានបំណង ចង់ស្វែងរកការពិត លើការសង្ស័យណាមួយពាក់ព័ន្ធនឹងមូលដ្ឋានទ័ពបរទេស នៅលើទឹកដីកម្ពុជា និងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញអំពីបញ្ហានេះ តែផ្ទុយទៅវិញ ក្នុងករណីដែល រកមិនឃើញភស្តុតាង ឬទឡ្ហីករណ៍ច្បាស់លាស់ទេ សូមឱ្យអាមេរិកបញ្ឈប់ជាបន្ទាន់ នូវការប្រឌិតញុះញង់ លាបពណ៌ និងជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ប្រទេសកម្ពុជាតទៅទៀត៕

ថ្ងៃសុក្រ ១២រោច ខែបុស្ស សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩